ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ៩១/០៩-អាកាសចរសៀមរាបអន្តរជាតិ**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៩**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **សេង រ៉ូចហ៊ុន**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **អាំង អេងថុង**

## ភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : **ក្រុមហ៊ុន អាកាសចរសៀមរាបអន្តរជាតិ**

អាសយដ្ឋាន : ភូមិគោកដូង សង្កាត់ទឹកវិល ក្រុងសៀមរាប ខេត្តសៀមរាប

ទូរស័ព្ទ : ០១៦ ៦២៥ ០០០ លេខទូរសារ : គ្មាន

តំណាងភាគីនិយោជក :

១- Mr. Terence F. Aton នាយកក្រុមហ៊ុន

២- លោក ហួ លីហួរ មេធាវី

៣- លោកស្រី ឈើ វ៉ា រដ្ឋបាល និង ធនធានមនុស្ស

៤- លោក សេង ពិសិដ្ឋ ជំនួយការមេធាវី

២- ភាគីកម្មករនិយោជិត

ឈ្មោះ : -សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍ និង សេវាកម្មកម្ពុជា

-សហជីពកម្មករនិយោជិតអាកាសចរណ៍សៀមរាបអន្តរជាតិសេវាកម្មម្ហូបអាហារ

អាសយដ្ឋាន : ផ្ទះលេខ ១២៥១ ក្រុម១ ភូមិគោកដូង ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប

លេខទូរស័ព្ទ : ០១២ ៩៦៥ ០៩១ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោក សុខ ណារិទ្ធិ — អនុប្រធាន CTSWF
២- លោក ទូ ចាន់ឌី — គណៈកម្មការអចិន្ត្រៃសហព័ន្ធ CTSWF
៣- លោក ដាំ សុផាត — គណៈកម្មការដោះស្រាយវិវាទការងារ
៤- លោក ម៉ម រិទ្ធី — គណៈកម្មការដោះស្រាយវិវាទការងារ
៥- លោក យ៉ាន់ សុធា — អនុប្រធានសហជីព
៦- លោក នន់ សីហា — លេខាធិការសហជីព
៧- លោក លួន ថាវុឌ្ឍ — ទីប្រឹក្សាសហជីព

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនសងប្រាក់ជំងឺចិត្តដល់កម្មករនិយោជិតចំនួន ៧៥ នាក់ ដែលក្រុមហ៊ុនបានផ្ដាច់កិច្ចសន្យាការងារ (និយោជកមិនទទួលយកការទាមទារនេះទេ) ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលទទួលអំណាចក្នុងការចេញសេចក្ដីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្ដីពីការងារឆ្នាំ១៩៩៧ ប្រកាសស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាលលេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ និងប្រកាសស្ដីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្ដាលលេខ ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្ដីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្ដីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្ដីអំពីការមិនសះជា លេខ ៦៥១ ម.ក.ប.វ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៩ ។

## សវនាការ និង សង្ខេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្ដាល

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្ដាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ** : ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៩ ( វេលាម៉ោង ០៩:៣០ នាទី ព្រឹក )

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប បានទទួលបណ្តឹងរបស់កម្មករនិយោជិត ស្តីអំពីការបិទអាជីវកម្មផ្នែកសេវាកម្មម្ហូបអាហារ ដោយមិនបានបង់សោហ៊ុយជំងឺចិត្តដល់កម្មករនិយោជិត។ បន្ទាប់ពីទទួលបានបណ្តឹងនេះមក មន្ទីរការងារក៏បានចាត់មន្ត្រីចុះទៅផ្សះផ្សា ប៉ុន្តែការផ្សះផ្សានោះពុំទទួលបានលទ្ធផលសះជាទេ ។ ដូច្នេះ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប បានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយជាបន្ត នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ ដោយពុំបានទទួលលទ្ធផលសះជានឹងគ្នាលើការទាមទារចំនួន ០១ ចំណុច។ ចំណុចមិនសះជាចំនួន ០១ ចំណុចនេះ បានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៩។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតប្រចាំក្រុមហ៊ុន មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០១ ចំណុចនេះ នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ វេលាម៉ោង ០៩:៣០ នាទីព្រឹក ។

ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការតាមការកោះអញ្ជើញរបស់អាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសាកសួរព័ត៌មានផ្សេងៗដែលទាក់ទងទៅនឹងវិវាទនេះ និងបានព្យាយាមធ្វើការផ្សះផ្សាចំណុចមិនសះជាចំនួន ០១ ចំណុចនេះបន្ថែមទៀត ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា និងដោះស្រាយដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម :

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី :** គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតប្រគល់សិទ្ធិរបស់នាយកក្រុមហ៊ុនអាកាសចរសៀមរាបអន្តរជាតិ ជូនក្រុមមេធាវី អេចប៊ី អេស និង ខន់សាល់ចិន ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៩ ។

២- សារណាសង្ខេបនៃវិវាទការងាររបស់ក្រុមហ៊ុនអាកាសចរសៀមរាបអន្តរជាតិ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ ។

៣- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុនអាកាសចរសៀមរាបអន្តរជាតិ លេខ ២០០៤ ៣៣.ចបព ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ ។

៤- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុនអាកាសចរសៀមរាបអន្តរជាតិ ចុះបញ្ជិកាលេខ ០៥៦ ក.ក.ប.វ/អ.ធ.ក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៩ ។

៥- លិខិតរបស់នាយកចាត់ការទូទៅនៃក្រុមហ៊ុនអាកាសចរសៀមរាបអន្តរជាតិលេខ FT2009/004 TN ជំរាបជូនប្រតិភូ-តំណាងបុគ្គលិក និងកម្មករនិយោជិតផ្នែកផ្តល់ម្ហូបអាហារទាំងអស់ ស្តីពីការបិទសេវាកម្មផ្នែកផ្តល់ម្ហូបអាហារ និងការបញ្ចប់កិច្ចសន្យាការងារ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៩។

៦- លិខិតរបស់នាយកចាត់ការទូទៅនៃក្រុមហ៊ុនអាកាសចរសៀមរាបអន្តរជាតិលេខ FT2009/005 TN គោរពជូនប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប ស្តីពីការបិទសេវាកម្មផ្នែកផ្តល់ម្ហូបអាហារនៃក្រុមហ៊ុនអាកាសចរណ៍សៀមរាបអន្តរជាតិ នៅខេត្តសៀមរាប ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៩។

៧- លិខិតរបស់នាយកចាត់ការទូទៅនៃក្រុមហ៊ុនអាកាសចរសៀមរាបអន្តរជាតិលេខ FT2009/006 TN ជំរាបជូនប្រតិភូ-តំណាងបុគ្គលិក និងកម្មករនិយោជិតផ្នែកផ្តល់ម្ហូបអាហារទាំងអស់ ស្តីពីការបដិសេធចំពោះសំណើសំណងជំងឺចិត្តតាមមាត្រា ៩១ នៃច្បាប់ស្តីពីការងារ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ ២០០៩។

៨- លិខិតទទួលប្រាក់ទូទាត់បញ្ចប់ការងាររបស់កម្មករនិយោជិតចំនួន ៧៥ នាក់ ។

៩- លិខិតរបស់គណៈកម្មការអឺរ៉ុប ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការធ្វើបច្ចុប្បន្នភាពលើកទី៩ លើបញ្ជីសហគមន៍ក្រុមហ៊ុនអាកាសចរដឹកជញ្ជូនដែលស្ថិតនៅក្រោមបំរាមធ្វើប្រតិបត្តិការនៅក្នុងសហគមន៍ក្នុងក្របខ័ណ្ឌនៃការធ្វើនិយ័តកម្ម (EC) លេខ ២១១១/២០០៥-ក្រុមហ៊ុនអាកាសចរណ៍សៀមរាបអន្តរជាតិ ។

១០- លិខិតរបស់លេខាធិការដ្ឋានអាកាសចរស៊ីវិល លេខ ១២២០ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការជូនដំណឹងអំពីការព្យួរអាជ្ញាប័ណ្ណហោះហើរ ( Air Operator Certificate ) ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- សារណាស្តីពីវិវាទក្រុមហ៊ុនអាកាសចរសៀមរាបអន្តរជាតិ នៃសំណុំរឿង លេខ ៩១/០៩ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ ។

២- ពាក្យបណ្តឹងរបស់សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍ និងសេវាកម្មកម្ពុជា លេខ ៩១/០៩ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ គោរពជូនប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប ស្តីពីការប្តឹងក្រុមហ៊ុនអាកាសចរសៀមរាបអន្តរជាតិ ។

៣- សេចក្តីជូនដំណឹងរបស់សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍ និងសេវាកម្មកម្ពុជា នៃក្រុមហ៊ុនអាកាសចរសៀមរាបអន្តរជាតិ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ ។

៤- វិញ្ញាបនប័ត្របញ្ជាក់ភាពជាតំណាងបំផុតរបស់សហជីពកម្មករនិយោជិតអាកាសចរសៀមរាបអន្តរជាតិសេវាកម្មម្ហូបអាហារ លេខ ២៧១ ក.ក.ប.វ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ ។

៥- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពកម្មករនិយោជិតអាកាសចរណ៍សៀមរាបអន្តរជាតិសេវាកម្មម្ហូបអាហារ លេខ ៧៩២ ក.ក.ប.វ/វ.ក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ។

៦- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុនអាកាសចរសៀមរាបអន្តរជាតិ ចុះបញ្ជិកាលេខ ២០ ក.ប.វ.ខ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០០៩ ។

៧- លិខិតរបស់នាយកចាត់ការទូទៅនៃក្រុមហ៊ុនអាកាសចរសៀមរាបអន្តរជាតិលេខ FT2009/006 TN ជំរាបជូនប្រតិភូ-តំណាងបុគ្គលិក និងកម្មករនិយោជិតផ្នែកផ្តល់ម្ហូបអាហារទាំងអស់ ស្តីពីការបដិសេធចំពោះសំណើរសំណងជំងឺចិត្តតាមមាត្រា ៩១ នៃច្បាប់ស្តីពីការងារ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩។

៨- កំណត់ហេតុសាកសួរពតិមានពីតំណាងកម្មករនិយោជិតនៃក្រុមហ៊ុនអាកាសចរសៀមរាបអន្តរជាតិ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៩ ។

៩- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន អាកាសចរសៀមរាបអន្តរជាតិ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ ។

១០- លិខិតរបស់នាយកចាត់ការទូទៅនៃក្រុមហ៊ុន អាកាសចរសៀមរាបអន្តរជាតិលេខ FT2009/004 TN ជំរាបជូនប្រតិភូ-តំណាងបុគ្គលិក និងកម្មករនិយោជិតផ្នែកផ្តល់ម្ហូបអាហារទាំងអស់ ស្តីពីការបិទសេវាកម្មផ្នែកផ្តល់ម្ហូបអាហារ និងការបញ្ចប់កិច្ចសន្យាការងារ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៩។

១១- កំណត់ហេតុបញ្ជាក់ថា មន្ទីរការងារណាត់ជួបទាំងនិយោជក និងកម្មករនិយោជិត ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៩ ។

១២- កំណត់ហេតុប្រជុំចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន អាកាសចរសៀមរាបអន្តរជាតិ លេខ ៦៥១ ម.ក.ប.វ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៩។

២- កំណត់ហេតុដោះស្រាយវិវាទការងាររួមរបស់ក្រុមហ៊ុន អាកាសចរសៀមរាបអន្តរជាត ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៤៤៤ កប/អក/វក/លកអ. ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៤៤៥ កប/អក/វក/លកអរ.ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- ក្រុមហ៊ុន អាកាសចរសៀមរាបអន្តរជាតិ មានទីតាំងស្ថិតនៅភូមិគោកដូង សង្កាត់ទឹកវិល ក្រុងសៀមរាប ខេត្តសៀមរាប មានកម្មករនិយោជិតចំនួនប្រមាណ ១០០ នាក់។
- នៅក្នុងសំណុំរឿងនេះ ភាគីដើមបណ្តឹង គឺសហជីពកម្មករនិយោជិតអាកាសចរណ៍សៀមរាបអន្តរជាតិ សេវាកម្មម្ហូបអាហារ និងសហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍ និង សេវាកម្មកម្ពុជា។
- នៅក្នុងកំណត់ហេតុមិនសះជា ភាគីសហជីពបានទាមទារប្រាក់សោហ៊ុយជំងឺចិត្តដល់កម្មករនិយោជិតចំនួន ៧៥ នាក់ (នៅសេវាកម្មផ្នែកផ្គត់ម្ហូបអាហារ)ដែលក្រុមហ៊ុនបានផ្តាច់កិច្ចសន្យាការងារកាលពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៩។ តែនៅពេលសវនាការ ភាគីសហជីពបានបញ្ជាក់ថា ការទាមទារប្រាក់ជំងឺចិត្តនេះ គឺទាមទារសំរាប់តែកម្មករនិយោជិតចំនួន ៥៩ នាក់ ដែលមានអតីតភាពចាប់ពី ២ ឆ្នាំឡើងទៅតែប៉ុណ្ណោះ ដោយសារតែកម្មករនិយោជិតទាំងនេះមិនបានទទួលការជូនដំណឹងត្រឹមត្រូវតាមច្បាប់។ ចំពោះកម្មករនិយោជិត ១៦ នាក់ទៀត ដែលមានអតីតភាពចាប់ពី ២ ឆ្នាំចុះក្រោមនោះ សហជីពបានបញ្ជាក់ថា មិនទាមទារប្រាក់ជំងឺចិត្តទៀតទេ ដោយសារនិយោជកបានជូនដំណឹងដល់កម្មករនិយោជិតទាំងនោះត្រឹមត្រូវតាមច្បាប់ហើយ។

**ចំណុចវិវាទ: *ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនសងប្រាក់ជំងឺចិត្តដល់កម្មករនិយោជិតចំនួន ៧៥ នាក់ ដែលក្រុមហ៊ុនបានផ្តាច់កិច្ចសន្យាការងារ***

- ភាគីកម្មករនិយោជិតបានបញ្ជាក់ពីមូលហេតុនៃការទាមទារថា ភាគីនិយោជកមិនបានជូនដំណឹងត្រឹមត្រូវតាមរយៈពេលកំណត់ក្នុងមាត្រា ៧៥ នៃច្បាប់ស្តីពីការងារ ដល់កម្មករនិយោជិតដែលមានអតីតភាពការងារលើសពី ២ ឆ្នាំឡើងទៅ រហូតដល់ ១១ ឆ្នាំ។ ក្នុងការផ្តាច់កិច្ចសន្យាការងារ ពោលគឺការជូនដំណឹងនោះ មានរយៈពេលតិចជាងមួយខែ មុនថ្ងៃផ្តាច់កិច្ចសន្យាការងាររបស់កម្មករនិយោជិត ។ ដោយសារមូលហេតុនេះហើយទើបភាគីនិយោជក ត្រូវតែមានកាតព្វកិច្ចផ្តល់ប្រាក់សោហ៊ុយជំងឺចិត្តជូនកម្មករនិយោជិតទាំងនោះ តាមមាត្រា ៩១ នៃច្បាប់ស្តីពីការងារ។

- ភាគីនិយោជកមិនឯកភាពនឹងការទាមទារនេះទេ ដោយលើកហេតុផលថា ការបញ្ឈប់នេះនិយោជកមានហេតុផលត្រឹមត្រូវ ហើយចំពោះការជូនដំណឹងមិនត្រឹមត្រូវតាមរយៈពេលដែលច្បាប់កំណត់នោះ ភាគីនិយោជកបានទូទាត់ជាប្រាក់ជួសការជូនដំណឹងមិនគ្រប់រួចរាល់ហើយ ។
- ភាគីនិយោជកបានពន្យល់ពីមូលហេតុនៃការផ្ដាច់កិច្ចសន្យាការងារថា សេវាកម្មផ្នែកផ្គត់ម្ហូបអាហារជាផ្នែកមួយដែលត្រូវបានបង្កើតឡើងសម្រាប់ធ្វើអាហារ ដើម្បីបំរើភ្ញៀវដែលជិះយន្តហោះរបស់ក្រុមហ៊ុន អាកាសចរសៀមរាបអន្តរជាតិ ។ នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ក្រុមហ៊ុន អាកាសចរសៀមរាបអន្តរជាតិ បានផ្អាកដំណើរការរបស់ខ្លួន ដោយសារគណៈកម្មការអឺរ៉ុប បានចេញបំរាមហាមឃាត់ការហោះហើរ ។ នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៨ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានចេញលិខិតដើម្បីព្យួរអាជ្ញាប័ណ្ណ មិនឱ្យក្រុមហ៊ុនបន្តដំណើរការបន្តទៅទៀត រហូតដល់មានការសម្រេចសារជាថ្មីទៀត។ ប៉ុន្តែ ចាប់តាំងពីពេលផ្អាកការហោះហើរមក ផ្នែកផ្គត់ម្ហូបអាហារនៅតែមានការងារធ្វើដដែល ដោយក្រុមហ៊ុន បាងកកអ៊ែរវេស៍ បានទទួលទិញយកម្ហូបអាហារពីក្រុមហ៊ុន អាកាសចរសៀមរាបអន្តរជាតិ រហូតដល់ខែមិថុនា ឆ្នាំ២០០៩ ក្រុមហ៊ុន បាងកកអ៊ែរវេស៍ បានសម្រេចឈប់ទទួលទិញម្ហូបអាហារពីក្រុមហ៊ុន អាកាសចរសៀមរាបអន្តរជាតិ រហូតដល់សព្វថ្ងៃ ដោយសារតែក្រុមហ៊ុន បាងកកអ៊ែរវេស៍ បានបើកផ្នែកនេះដោយខ្លួនឯង។ មូលហេតុនេះ ទើបខ្លួនសម្រេចបញ្ចប់កិច្ចសន្យាការងារជាមួយកម្មករនិយោជិតនៅក្នុងផ្នែកម្ហូបអាហារនេះទាំងអស់តែម្ដង ។ ភាគីកម្មករនិយោជិតមិនជំទាស់នឹងការអះអាងនេះទេ ។
- នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៩ និយោជកបានជូនដំណឹងដល់កម្មករនិយោជិតចំនួន ៧៥ នាក់ ដែលបំរើការងារនៅក្នុងផ្នែកផ្គត់ម្ហូបអាហារ ស្ដីពីការបិទសេវាកម្មផ្នែកផ្គត់ម្ហូបអាហារ និងការបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិត នៅផ្នែកនេះ នាថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៩។ ភាគីកម្មករនិយោជិតមិនជំទាស់នឹងការលើកឡើងនេះទេ ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ កម្មករនិយោជិតទាំង ៧៥ នាក់ បានទទួលប្រាក់បំណាច់ផ្សេងៗ រួមមានៈ (១)-ប្រាក់ខែចុងក្រោយប្រចាំខែឧសភា ឆ្នាំ២០០៩, (២)-ប្រាក់បំណាច់កិច្ចសន្យាការងារ, (៣)-ប្រាក់ឧបត្ថម្ភបន្ថែម, (៤)-ប្រាក់ទូទាត់ជួសការជូនដំណឹងមុន (ចំពោះកម្មករនិយោជិតដែលក្រុមហ៊ុនជូនដំណឹងមិនគ្រប់រយៈពេលដែលកំណត់ដោយច្បាប់ការងារ), និង(៥)-ប្រាក់ទូទាត់ថ្ងៃឈប់សំរាកប្រចាំឆ្នាំដែលមិនទាន់ប្រើ ។ ប៉ុន្តែ ភាគីនិយោជកមិនបានផ្ដល់ប្រាក់ជំងឺចិត្តស្របតាមមាត្រា ៩១ នៃច្បាប់ស្ដីពីការងារនោះទេ ។

- ភាគីកម្មករនិយោជិតយល់ឃើញថា មាត្រា ៩១ នៃច្បាប់ស្តីពីការងារ តម្រូវឱ្យនិយោជកមានកាតព្វកិច្ចបង់សោហ៊ុយជំងឺចិត្តជូនកម្មករនិយោជិត ព្រោះកិច្ចសន្យាការងារត្រូវបានរំលាយតាមឆន្ទៈផ្ទាល់របស់ភាគីនិយោជក ដោយគ្មានហេតុផលត្រឹមត្រូវ...។
- ភាគីនិយោជកយល់ឃើញថា មាត្រា ៩១ នៃច្បាប់ស្តីពីការងារអនុវត្តបានតែក្នុងករណីនិយោជកមិនមានហេតុផលត្រឹមត្រូវក្នុងការផ្តាច់កិច្ចសន្យាការងាររបស់កម្មករនិយោជិត ។ ចំពោះពាក្យថា ហេតុផលត្រឹមត្រូវនោះ មានអត្ថន័យផ្សេងពីការជូនដំណឹងមិនគ្រប់តាមរយៈពេលកំណត់ ដោយច្បាប់ស្តីពីការងារ ។ ចំពោះការជូនដំណឹងមិនគ្រប់ និយោជកមានកាតព្វកិច្ចទូទាត់ប្រាក់ជូនកម្មករនិយោជិតឱ្យគ្រប់តាមចំនួនថ្ងៃដែលខ្វះនោះ តាមមាត្រា ៧៧ នៃច្បាប់ស្តីពីការងារ ។ ចំពោះកម្មករនិយោជិតណាដែលនិយោជកមិនបានជូនដំណឹងគ្រប់រយៈពេលដែលច្បាប់បានកំណត់នោះ និយោជកបានផ្តល់ប្រាក់ទូទាត់ជួសការជូនដំណឹងដែលមិនត្រឹមត្រូវតាមច្បាប់កំណត់នោះរួចរាល់អស់ហើយ ។ ភាគីកម្មករនិយោជិតទទួលស្គាល់ថា ពិតជាបានទទួលប្រាក់ជួសការជូនដំណឹងនោះអស់ហើយដែរ ។ ភាគីនិយោជកលើកឡើងទៀតថា កម្មករនិយោជិតទាំងនោះបានទទួលយកប្រាក់ ហើយបានចុះបត្តលេខាថា បានទទួលប្រាក់បំណាច់ផ្សេងៗ តាមច្បាប់អស់ហើយ និងមិនទាមទារអ្វីទៀតទេ ។
- ភាគីសហជីពបានលើកឡើងថា ការទទួលយកនោះគ្រាន់តែជាការទទួលយកជាបណ្តោះអាសន្នទេ ហើយសហជីព ក៏បានធ្វើលិខិតមួយស្តីពីការទាមទារប្រាក់ជំងឺចិត្តជូននិយោជករួចហើយដែរ ។ ម្យ៉ាងទៀត តាមច្បាប់ ចំពោះកិច្ចព្រមព្រៀងណាធ្វើឡើងមិនស្របទៅនឹងច្បាប់ គឺត្រូវទុកជាមោឃៈ ។

## ហេតុផលនៃសេចក្តីសម្រេចៈ

**ចំណុចវិវាទៈ ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនសងប្រាក់ជំងឺចិត្ត ដល់កម្មករនិយោជិតចំនួន ៥៩ នាក់ ដែលក្រុមហ៊ុនបានផ្តាច់កិច្ចសន្យាការងារ**

នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកសងប្រាក់ជម្ងឺចិត្ត ដល់កម្មករនិយោជិតចំនួន ៧៥ នាក់ ដែលក្រុមហ៊ុនបានផ្តាច់កិច្ចសន្យាការងារ ដោយមូលហេតុថា ភាគីនិយោជកជូនដំណឹងទៅកម្មករនិយោជិតមិនបានគ្រប់ចំនួនតាមច្បាប់ស្តីពីការងារកំណត់ ប៉ុន្តែនៅពេលសវនាការ ភាគីកម្មករនិយោជិតបានកែប្រែការទាមទារពីចំនួនកម្មករ ៧៥ នាក់ មកជាកម្មករនិយោជិតចំនួន ៥៩ នាក់វិញ ដោយអះអាងថា កម្មករចំនួន ១៦ នាក់ទៀត ត្រូវបានជូនដំណឹងស្តីពីការបញ្ចប់កិច្ចសន្យាការងារត្រឹមត្រូវ និងបានទទួលប្រាក់ខែ និងអត្ថប្រយោជន៍ផ្សេងៗរួចហើយ ។ ភាគីនិយោជកលើកឡើងថា នៅពេលដែលនិយោជកជូនដំណឹងមិនគ្រប់ចំនួនតាមរយៈពេលដែលច្បាប់កំណត់ មុនពេលដែលកិច្ចសន្យាការងារត្រូវបានបញ្ចប់ និយោជកបានទូទាត់ប្រាក់ជួសការជូនដំណឹង

រួចរាល់ហើយ ហើយភាគីកម្មករនិយោជិតក៏ទទួលបានរួចរាល់អស់ហើយដែរ ។ និយោជកគ្មានកាតព្វកិច្ចតាមផ្លូវច្បាប់នៅក្នុងការបង់សោហ៊ុយជំងឺចិត្តជូនកម្មករនិយោជិតនោះទេ ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើភាគីកម្មករនិយោជិតមានសិទ្ធិទទួលបានសោហ៊ុយជំងឺចិត្តដែរ ឬទេ?

មាត្រា ៩១ នៃច្បាប់ស្តីពីការងារចែងថា *"ការរំលាយកិច្ចសន្យាការងារតាមឆន្ទៈផ្ទាល់នៃភាគីណាមួយ ដោយគ្មានហេតុផលត្រឹមត្រូវនោះ អាចបើកសិទ្ធិឱ្យភាគីម្ខាងទៀតទារសងសោហ៊ុយជម្ងឺចិត្តបាន ។*

*សោហ៊ុយជំងឺចិត្តនេះមិនត្រូវច្រឡំគ្នាជាមួយនឹងប្រាក់បំណាច់ទូទាត់ជូសការឱ្យដំណឹងមុន ឬជាមួយនឹងប្រាក់បំណាច់បណ្តេញចេញទេ ។*

*កម្មករនិយោជិតអាចទាមទារប្រាក់បំណាច់បើកផ្តាច់មួយ ដែលមានចំនួនស្មើនឹងប្រាក់បំណាច់បណ្តេញចេញ ។ ក្នុងករណីនេះ កម្មករនិយោជិតត្រូវបានរួចពីកាតព្វកិច្ច ដែលត្រូវផ្តល់ភស្តុតាងបញ្ជាក់ពីការខូចខាតរបស់ខ្លួន ។"*

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៨៤/០៨-ទ្រីនុងហ្គាល់ កូមារ៉ា ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការបកស្រាយថា *"កម្មករនិយោជិតមិនមានសិទ្ធិទទួលបានជំងឺចិត្តទេ ដោយហេតុថា និយោជកមានហេតុផលសមរម្យសម្រាប់ការបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិត ។"* (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *៨៤/០៨-ទ្រីនុងហ្គាល់ កូមារ៉ា*) ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ខ្លឹមសារនៃមាត្រា និងសេចក្តីបង្គាប់ខាងលើនេះ មានន័យថា ភាគីកម្មករនយោជិត អាចទទួលបាននូវសោហ៊ុយជំងឺចិត្ត នៅពេលមានការរំលាយកិច្ចសន្យាការងារតាមឆន្ទៈផ្ទាល់នៃភាគីនិយោជក ដោយគ្មានហេតុផលត្រឹមត្រូវ ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាបន្តថា តើភាគីនិយោជកនៅក្នុងសំណុំរឿងនេះ មានមូលហេតុត្រឹមត្រូវនៅក្នុងការផ្តាច់កិច្ចសន្យាការងាររបស់កម្មករនិយោជិតដែរ ឬទេ?

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រា ៦៧ កថាខណ្ឌទី ២ នៃច្បាប់ស្តីពីការងារថា *"ប្រសិនបើថិរវេលាសរុបនៃទំនាក់ទំនងការងារលើសពីពីរឆ្នាំ កិច្ចសន្យាការងារនេះក្លាយទៅជាកិច្ចសន្យាមានថិរវេលាមិនកំណត់ ។"* (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *១០/០៣-ហ្សាក់ស៊ីនតិច ចំណុចវិវាទទី១ លេខ០២/០៤-កាំបូឌីយ៉ាណា និង លេខ៣៦/០៦-ម៉ុនដូតិច្ស ចំណុចវិវាទទី២ ។)*

នៅក្នុងសំណុំរឿងនេះ កម្មករនិយោជិតទាំង ៥៩ នាក់នោះ មានអតីតភាពការងារលើសពីពីរឆ្នាំ ។ ហេតុដូច្នេះ កិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំងនោះ ជាប្រភេទកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ។

មាត្រា ៧៤ នៃច្បាប់ស្តីពីការងារចែងថា *"កិច្ចសន្យាការងារដែលមានថិរវេលាមិនកំណត់ អាចរំលាយតាមឆន្ទៈភាគីតែម្ខាងបាន ។ ការរំលាយកិច្ចសន្យានេះ ត្រូវអនុវត្តទៅតាមរបៀបឱ្យដំណឹងមុន ជាលាយលក្ខណ៍អក្សរដែល*

*ភាគីមានបំណងចង់រំលាយកិច្ចសន្យាត្រូវឱ្យដំណឹងទៅភាគីម្ខាងទៀត ។ ក៏ប៉ុន្តែ គ្មានការបញ្ឈប់ណាមួយអាចធ្វើទៅបានដោយគ្មានហេតុផលសមរម្យទាក់ទងនឹងសម្បទា ឬចរិយានៃកម្មករនិយោជិត យោលទៅលើភាពចាំបាច់នៃដំណើររបស់សហគ្រាស របស់គ្រឹះស្ថាន ឬ របស់ក្រុមឡើយ ។"*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្នុងករណីដែលភាគីនៃកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ អាចរំលាយតាមឆន្ទៈរបស់ភាគីនិយោជកតែម្ខាងបាន ភាគីនិយោជកដែលមានបំណងចង់រំលាយកិច្ចសន្យាការងារនេះ ត្រូវមានមូលហេតុស្របច្បាប់ នៅក្នុងការបញ្ចប់កិច្ចសន្យាការងារនេះ ដូចជា ហេតុផលសមរម្យទាក់ទងនឹងសម្បទា ឬ ចរិយានៃកម្មករនិយោជិត យោលទៅលើភាពចាំបាច់នៃដំណើររបស់សហគ្រាស របស់គ្រឹះស្ថាន។

នៅក្នុងសំណុំរឿងនេះ ភាគីក្រុមហ៊ុនមិនអាចបន្តដំណើរការផ្គត់ម្ហូបអាហារបន្តទៀតបានទេ ដោយហេតុផលថា ជើងហោះហើររបស់ក្រុមហ៊ុនអាកាសចរសៀមរាបអន្តរជាតិ ត្រូវបានព្យួរអាជ្ញាបណ្ណ័ហោះហើរ ដោយលេខាធិការដ្ឋានអាកាសចរស៊ីវិល និងដោយសារក្រុមហ៊ុន បាងកកអ៊ែរវេស៍ ផ្តាច់ការទទួលផ្គត់ផ្គង់ម្ហូបអាហារពីក្រុមហ៊ុនអាកាសចរសៀមរាបអន្តរជាតិ។ កម្មករនិយោជិតក៏មិនជំទាស់នូវមូលហេតុទាំងនេះដែរ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីនិយោជកមានមូលហេតុសមស្របនៅក្នុងការផ្តាច់កិច្ចសន្យាការងាររបស់កម្មករនិយោជិតទាក់ទងនឹងភាពចាំបាច់នៃដំណើរការរបស់ក្រុមហ៊ុន។

ភាគីកម្មករនិយោជិតបញ្ជាក់ថា មូលហេតុនៃការទាមទារប្រាក់ជំងឺចិត្តនេះ ដោយសារហេតុផលនៃការជូនដំណឹងមិនគ្រប់គ្រាន់។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា គោលបំណងនៃការជូនដំណឹងរបស់ភាគីនិយោជកដល់កម្មករនិយោជិត គឺក្នុងគោលដៅជូនដំណឹងដល់កម្មករ ពីឆន្ទៈរបស់និយោជកក្នុងការផ្តាច់កិច្ចសន្យាការងារ ក៏ដូចជាក្នុងគោលបំណង ដើម្បីអាចឱ្យកម្មករនិយោជិតត្រៀមខ្លួន ត្រូវស្វែងរកការងារថ្មីជាដើម ។ល។ នៅក្នុងសំណុំរឿងនេះ ភាគីនិយោជកឯកភាពថា មានកម្មករនិយោជិតមួយចំនួន ដែលភាគីនិយោជកជូនដំណឹងមិនគ្រប់តាមការកំណត់របស់ច្បាប់ តែនិយោជកបានធ្វើការទូទាត់ប្រាក់ជួសការជូនដំណឹងរួចរាល់ហើយដែរ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ប្រាក់ជួសការជូនដំណឹងមុននេះ គឺ ដើម្បីទូទាត់ការដែលកម្មករនិយោជិតត្រូវសម្រាកពីការងារ ដើម្បីរកការងារធ្វើ ។

មាត្រា ៧៧ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ចែងថាៈ "*ការរំលាយកិច្ចសន្យាការងារតាមឆន្ទៈនៃនិយោជកតែឯកឯងគ្មានអោយដំណឹងមុន ឬ **មិនគោរពតាមរយៈពេលនៃការអោយដំណឹងមុន** តំរូវអោយនិយោជកចេញប្រាក់ទូទាត់ដល់កម្មករនិយោជិតមានចំនួនស្មើគ្នានឹងប្រាក់ឈ្នួល ហើយនិងអត្ថប្រយោជន៍គ្រប់ប្រភេទដែលកម្មករនិយោជិតត្រូវបានក្នុងរយៈពេលអោយដំណឹងមុន ដែលគេមិនបានគោរពត្រឹមត្រូវ ។"*

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីនិយោជកបានបំពេញកាតព្វកិច្ចដូចមានចែងនៅក្នុងមាត្រាខាងលើនេះរួចរាល់ហើយ ។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីនិយោជកមានហេតុផលច្បាស់លាស់ និងសមហេតុសមផល ហើយភាគីកម្មករនិយោជិតមិនមានសិទ្ធិទទួលបានសោហ៊ុយជំងឺចិត្តបានទេ ពីព្រោះការបិទផ្នែកផ្តល់ម្ហូបអាហារនេះ និយោជកមានមូលហេតុសមស្របតាមច្បាប់ស្តីពីការងារ ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាសម្រេចបដិសេធការទាមទាររបស់ភាគីកម្មករនិយោជិតឱ្យក្រុមហ៊ុន សងប្រាក់ជំងឺចិត្ត ដល់កម្មករនិយោជិតចំនួន ៥៩ នាក់ ដែលក្រុមហ៊ុនបានផ្តាច់កិច្ចសន្យាការងារ ។

## សម្រេច និង បង្គាប់

**ចំណុចវិវាទ:** សម្រេចបដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យក្រុមហ៊ុនសងប្រាក់ជំងឺចិត្តដល់កម្មករនិយោជិតចំនួន ៥៩ នាក់ ដែលក្រុមហ៊ុនបានផ្តាច់កិច្ចសន្យាការងារ ។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **សេង ទួចហ៊ុន**

ហត្ថលេខា: ------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **អន ណាន**

ហត្ថលេខា: ------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **អ៊ាំង អេងថុង**

ហត្ថលេខា: ------------------------------------